# ព្រះរាជក្រម

នស/រកម/១០០០/០៩

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីសម្តេចនាយករដ្ឋមន្ត្រី និង អំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រម លើពិធីសារលើការធ្វើវិសោធនកម្មទៅលើកិច្ចព្រមព្រៀងស្តីពីតំរោងអនុគ្រោះពន្ធគយរួមសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ធ្វើនៅទីក្រុងបាងកក នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើក ទី ៣ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ : ៕

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើពិធីសារលើការធ្វើវិសោធនកម្ម នៅលើកិច្ចព្រមព្រៀងស្តីអំពីគំរោងអនុគ្រោះពន្ធគយរួមសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន

### ស្តីពីការអនុម័តយល់ព្រមលើពិធីសារលើការធ្វើវិសោធនកម្ម
### ទៅលើកិច្ចព្រមព្រៀងស្តីអំពីគំរោងអនុគ្រោះពន្ធគយរួម
### សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន

មាត្រា ១.-

អនុម័តយល់ព្រមលើពិធីសារលើការធ្វើវិសោធនកម្មទៅលើកិច្ចព្រមព្រៀងស្តីអំពីគំរោងអនុគ្រោះពន្ធគយរួមសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ធ្វើនៅទីក្រុងបាងកក នាថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារខាងលើនេះ ។ល។

រាជធានីភ្នំពេញថ្ងៃទី២១ ខែ តុលា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានចំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ហត្ថលេខា**

លេខ : ១៩៦ ច.ល **ហោ ណាំហុង**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី [illegible] ខែតុលា ឆ្នាំ២០០០

អគ្គលេខាធិការរាជរដ្ឋាភិបាល

៣២១

## ពិធីសារនៃការធ្វើវិសោធនកម្មទៅលើ
## កិច្ចព្រមព្រៀងអំពីគំរោងអនុគ្រោះពន្ធគយរួម សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាំ សាធារណរដ្ឋឥណ្ឌូណេស៊ី ប្រទេសម៉ាឡេស៊ី ប្រទេសហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី និងព្រះរាជាណាចក្រថៃឡង់ដ៍ ដែលជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)

**ដោយកត់សំគាល់** លើកិច្ចព្រមព្រៀងស្តីពីគំរោងអនុគ្រោះពន្ធគយរួម សំរាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ាន ដែលបានចុះហត្ថលេខានៅសិង្ហបុរី កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩២

**ដោយរំលឹកឡើងវិញ** អំពីពិធីសារនៃការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការជំរុញសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន (១៩៩២) ដែលបានចុះហត្ថលេខាដោយប្រមុខរដ្ឋាភិបាល នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ នៅទីក្រុងបាងកក ដែលឆ្លុះបញ្ចាំងពីការជំរុញគំរោងអនុគ្រោះពន្ធគយរួម សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ានពីឆ្នាំ២០០៨ ចុះមកឆ្នាំ២០០៣

**ដោយទទួលស្គាល់** លើការចាំបាច់ធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងដែលឆ្លើយតបទៅនឹងការអភិវឌ្ឍន៍ថ្មីៗនៅក្នុងអាស៊ាន

**បានព្រមព្រៀងគ្នាដូចខាងក្រោម :**

### មាត្រា១

មាត្រា២ កថាខ័ណ្ឌទី៣, ៥ និង៦ នៃកិច្ចព្រមព្រៀងត្រូវបានធ្វើវិសោធនកម្ម ហើយត្រូវអានដូចខាងក្រោមនេះ :

៣. ការលើកលែងនៅក្នុងប្រព័ន្ធចុះសំរុងគ្នា (Harmonized System – HS) ដែលមាន៨/៩ខ្ទង់ សំរាប់ទំនិញជាក់លាក់ ត្រូវបានអនុញ្ញាតចំពោះប្រទេសជាសមាជិកទាំងឡាយណាដែលពុំទាន់ត្រៀមខ្លួនជាស្រេចក្នុងការដាក់បញ្ចូលទំនិញនោះទៅក្នុង CEPT នៅឡើយ ។ សំរាប់ទំនិញជាក់លាក់ ដែលមាន

វេទយិតភាព (sensitive) ចំពោះប្រទេសសមាជិក ដោយយោងទៅតាមមាត្រា១(៣) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការជំរុញសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន ប្រទេសសមាជិកអាចដកទំនិញចេញពីគំរោង CEPT ប៉ុន្តែមិនអាចទទួលសម្បទានដែលគេផ្តល់អោយចំពោះទំនិញប្រភេទនេះឡើយ ។ ទំនិញដែលដកចេញជាបណ្តោះអាសន្ននេះត្រូវដាក់បញ្ចូលក្នុងគំរោង CEPT អោយបានអស់នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០០។

៥. ទំនិញកម្មន្តសាលទាំងអស់ រួមទាំងទំនិញមូលធន និងផលិតផលកសិកម្មផង ត្រូវតែស្ថិតនៅក្នុងគំរោង CEPT។ ទំនិញទាំងនោះ ជាស្វ័យប្រវត្តិត្រូវតែស្ថិតនៅក្នុងកម្មវិធីកាត់បន្ថយពន្ធ ដែលមានចែងនៅក្នុងមាត្រា៤ នៃកិច្ចព្រមព្រៀងដែលបានកែសំរួលនៅក្នុងមាត្រា៣នៃពិធីសារនេះ ។ ពាក់ព័ន្ធនឹងមុខទំនិញនៅក្នុង PTA កម្មវិធីកាត់បន្ថយពន្ធ ដែលមានចែងក្នុងមាត្រា៤(ក) នៅក្នុងមាត្រា៣ នៃពិធីសារនេះ នឹងត្រូវអនុវត្តបាន តែត្រូវចាប់អារម្មណ៍លើអត្រាពន្ធបន្ទាប់ពីការកំណត់ដែននៃការអនុគ្រោះពន្ធ (margin of preference – MOP) ដែលលើកឡើងចាប់ពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩២ ។

៦. រាល់មុខទំនិញទាំងឡាយណាដែលស្ថិតនៅក្រោម PTA តែមិនស្ថិតនៅក្នុងបញ្ជីកាត់បន្ថយពន្ធរបស់គំរោង CEPT ត្រូវតែបន្តទទួលការអនុគ្រោះពន្ធ (margin of preference – MOP) ដែលកំណត់ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩២ ។

## មាត្រា២

មាត្រា៣ នៃកិច្ចព្រមព្រៀងត្រូវបានធ្វើវិសោធនកម្មហើយត្រូវអានដូចខាងក្រោមនេះ:

កិច្ចព្រមព្រៀងនេះមានសុពលភាពលើបណ្តាទំនិញកម្មន្តសាលទាំងអស់ រួមទាំងទំនិញមូលធន និងផលិតផលកសិកម្មផង ។

## មាត្រា៣

មាត្រា៤ នៃកិច្ចព្រមព្រៀងនេះត្រូវប្តូរដោយឃ្លាដូចខាងក្រោម :

កម្មវិធីនៃការកាត់បន្ថយពន្ធ និងការទទួលសម្បទាន

ក) **កម្មវិធីនៃការកាត់បន្ថយពន្ធ** (Schedule of Tariff Reduction)

១. ប្រទេសសមាជិកបានព្រមព្រៀងលើកម្មវិធីកាត់បន្ថយពន្ធអនុគ្រោះដូចខាងក្រោមនេះ :

ក) ការកាត់បន្ថយពន្ធលើអត្រាមានស្រាប់ ២០ ភាគរយ ត្រូវសំរេចក្នុងរយៈពេល ៥ឆ្នាំ គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៣ ដោយគោរពកម្មវិធីនៃការកាត់បន្ថយពន្ធគយ ដែលត្រូវបានសំរេចដោយប្រទេសសមាជិកនីមួយៗដែលនឹងត្រូវគេប្រកាសនៅពេលចាប់ផ្តើមកម្មវិធី ។ ប្រទេសសមាជិកនីមួយៗ ត្រូវបានលើទឹកចិត្តអោយរៀបចំការកាត់បន្ថយពន្ធប្រចាំឆ្នាំ តាមរូបមន្ត (X - 20) % /5 ដែល X ស្មើនឹងអត្រាពន្ធបច្ចុប្បន្នរបស់ប្រទេសសមាជិកនីមួយៗ ។

ខ) ការកាត់បន្ថយពន្ធពីអត្រា២០ភាគរយ ឬទាបជាងនេះ ត្រូវតែអនុវត្តអោយបានសំរេចក្នុងរយៈពេល៥ឆ្នាំ ។ អត្រាពន្ធដែលត្រូវកាត់បន្ថយត្រូវមាន ៥ ភាគរយ ជាអប្បបរិមា ក្នុងការកាត់បន្ថយម្តងៗ ។ កម្មវិធីកាត់បន្ថយ ដែលត្រូវសំរេចដោយប្រទេសសមាជិកនិមួយៗ ត្រូវប្រកាសផ្សាយនៅពេលដែលកម្មវិធីនោះចាប់ផ្តើមអនុវត្ត ។

គ) សំរាប់ទំនិញដែលមានអត្រាពន្ធពី២០ភាគរយ ឬទាបជាងនេះគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៣ ប្រទេសសមាជិកត្រូវសំរេចចិត្តលើកម្មវិធីកាត់បន្ថយពន្ធ ហើយត្រូវប្រកាសកម្មវិធីនេះនៅពេលចាប់ផ្តើមអនុវត្ត ។

២. កម្មវិធីនៃការកាត់បន្ថយពន្ធគយខាងលើនឹងមិនរារាំងដល់ប្រទេសសមាជិកអោយកាត់បន្ថយពន្ធគយរបស់ខ្លួនមកដល់ ០ និង ៥ ភាគរយភ្លាមៗនោះឡើយ ឬអោយប្រទេសជាសមាជិកនោះប្រកាន់យកនូវកម្មវិធីជំរុញការកាត់បន្ថយពន្ធគយនោះឡើយ ។

ខ) **ការទទួលសម្បទាន** **(Enjoyment of Concessions)**

ពាក់ព័ន្ធនឹងមាត្រា៤ (ក)(១ខ) និង ៤(ក)(១គ) នៃកិច្ចព្រមព្រៀងនេះ ទំនិញដែលមានអត្រាពន្ធ២០ភាគរយ ឬទាបជាង ត្រូវទទួលសម្បទានដោយស្វ័យប្រវត្តិ ។

## មាត្រា៤

ឃ្លាដូចខាងក្រោមនេះ ត្រូវដាក់បញ្ចូលបន្ទាប់ពីមាត្រាទី៩ ជាមាត្រា៩ក នៃកិច្ចព្រមព្រៀងនេះ :

**ការចូលរបស់សមាជិកថ្មី**

សមាជិកថ្មីរបស់អាស៊ានត្រូវតែចូលរួមក្នុងកិច្ចព្រមព្រៀងនេះតាមកាល និងល័ក្ខខ័ណ្ឌដែលស្របគ្នាទៅតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌក្នុងការជំរុញសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន ឆ្នាំ១៩៩២ និងកិច្ចព្រមព្រៀងនេះ ដែលត្រូវមានការព្រមព្រៀងគ្នារវាងសមាជិកចាស់ និងសមាជិកថ្មី ។

**មាត្រា៥**

ពិធីសារនេះនឹងចូលជាធរមានក្រោមការផ្តល់ និងទទួលលិខិតូបករណ៍សច្ចាប័នដោយប្រទេសជាសមាជិកទៅអគ្គលេខាធិការអាស៊ាន ដែលមិនត្រូវធ្វើអោយយឺតជាងថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ ឡើយ។

ពិធីសារនេះត្រូវតំកល់ទុកដោយអគ្គលេខាធិការអាស៊ានដែលត្រូវផ្តល់ជូនប្រទេសសមាជិកនិមួយៗ ជាបន្ទាន់នូវច្បាប់ចំឡងត្រឹមត្រូវមួយច្បាប់ ។

**ដើម្បីជាសក្ខីភាពតទៅមុខ** ហត្ថលេខីខាងក្រោមដែលបានទទួលសិទ្ធិប្រទានពីរដ្ឋាភិបាលរៀងខ្លួនបានចុះហត្ថលេខាលើពិធីសារ នៃការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីគំរោងអនុគ្រោះពន្ធគយរួម សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ។

ធ្វើនៅ ទីក្រុងបាងកកនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ ជាភាសាអង់គ្លេសចំនួនមួយច្បាប់ ។

តំណាងរដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាំ

ហត្ថលេខា

ABDUL RAHMAN TAIB

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងវត្ថុធាតុដើម

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី

ហត្ថលេខា

T. ARIWIBOWO

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី

ហត្ថលេខា

RAFIDAH AZIZ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មអន្តរជាតិ

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន

ហត្ថលេខា

RIZALINO S. NAVARRO

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី

ហត្ថលេខា

YEO CHEOW TONG

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍

ហត្ថលេខា

AMNUAY VIRAVAN

ឧបនាយករដ្ឋមន្ត្រី